# បុព្វកថា

សៀវភៅដែលមានចំណងជើងថា «ជីវិតលើផ្លូវបត់បែនទៅរកសន្តិភាព» ជាស្នាដៃនិពន្ធរបស់វរជនខ្មែរមួយរូប ដែលបានខិតខំរៀបចំចងក្រងនូវកម្រងអនុស្សាវរីយ៍ តាំងពីកុមារភាព រហូតដល់ទសវត្សរ៍ឆ្នាំ ១៩៨០ ។ យុវជនជំនាន់ក្រោយ និង អ្នកដែលមិនបានចូលប្រឡូកដោយផ្ទាល់ នៅក្នុងឆាកនយោបាយជាតិ ក្នុងក្របខ័ណ្ឌនៃរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ) គប្បីស្វែងយល់អំពីតម្លៃនៃស្នាដៃដ៏សំខាន់នេះ ។

ខ្លឹមសារនៃស្នាដៃនេះ ជាបឋម ផ្តោតលើជីវិតពិតរបស់អ្នកនិពន្ធផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់ក្រុមគ្រួសារ ដែលមានវាសនាបត់បែនទៅតាមវាសនានៃកម្ពុជា នាសម័យកោះសន្តិភាព (១៩៥៥-១៩៧០) និង សម័យព្យុះសង្ឃរានៃសង្គ្រាម និង បដិវត្តន៍បង្ហូរឈាម (១៩៧០-១៩៧៨) ដូចក្រុមគ្រួសារខ្មែរដទៃទៀតដែរ ។

បន្ថែមលើប្រវត្តិនៃក្រុមគ្រួសារលោកតាអៀង អ្នកនិពន្ធរួមចំណែកយ៉ាងសំខាន់ក្នុងការចែករំលែកនូវចំណេះដឹងជាក់ស្តែងអំពីសង្គមកម្ពុជា ដល់ជនានុជនជំនាន់ក្រោយ ដោយលោកជាសាក្សីម្នាក់នៃព្រឹត្តិការណ៍ជាតិ តាំងពីទសវត្សរ៍ឆ្នាំ ១៩៥០ នោះមក ។

ក្នុងខ្លឹមសារទី២នេះ លោកបានរំលឹកអំពីជីវភាពប្រចាំថ្ងៃរបស់អ្នកស្រែចម្ការដោយឆ្លុះបញ្ចាំងនូវមនោសញ្ចេតនាស្នេហាទឹកដី ភូមិកំណើត ដែលនៅសម័យនោះប្រជាពលរដ្ឋខ្មែរខំថែរក្សាប្រពៃណីជាតិ និង រស់នៅជាមួយគ្នាដោយសុខដុមរមនាក្នុងឯករាជ្យ និង សន្តិភាពក្រោយសង្គ្រាមឥណ្ឌូចិនលើកទី១ (១៩៤៦-១៩៥៤)។

អ្នកនិពន្ធបង្ហាញនូវការសោកស្ដាយ ចំពោះការបាត់បង់ទៅនូវសន្តិភាព ក្រោយព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ នៅក្រោមឥទ្ធិពលនៃសង្គ្រាមត្រជាក់ ដែលបង្កឡើងដោយសារមហិច្ឆិតានៃមហាអំណាចលោកសេរី និង កុម្មុយនីស្ត នៅដំណាក់កាលចុងក្រោយនៃសង្គ្រាមឥណ្ឌូចិនលើកទី២ (១៩៥៥-១៩៧៥) ។

ទន្ទឹមនឹងនេះ លោកក៏បានរំលឹកអំពីជីវិតសិក្សា ពីកម្រិតបឋមដល់កម្រិតឧត្ដម ដោយបានបោះជំហានឈានឡើង ដោយជោគជ័យជាលំដាប់ ពីសាលារៀននៅស្រុកស្រែចម្ការ រហូតដល់គ្រឹះស្ថានមធ្យម និង ឧត្ដមសិក្សា នៅរាជធានីភ្នំពេញ ។ ការសិក្សាផង និង ការចូលប្រឡូកក្នុងការងារជំណាលគ្នាផងនោះ នាំឲ្យលោកមានបទពិសោធន៍ក្នុងទំនាក់ទំនងសង្គម តាំងពីយុវវ័យ ទាំងនៅក្នុងទាំងនៅក្រៅប្រទេស ។

ទេពកោសល្យនេះ ជួយជំរុញឲ្យលោកបានចេញទៅសិក្សានៅប្រទេសបារាំង នៅឆ្នាំ ១៩៧៣ ហើយជីវិតផ្សងព្រេង នៅលើទឹកដីថ្មី ក៏បានចាប់ផ្ដើមឡើង ។ លោកបានរួចផុតពីភ្នក់ភ្លើងសង្គ្រាមក្នុងប្រទេសមែន ប៉ុន្តែជីវិតតែលតោលជាជនភៀសខ្លួន តម្រូវឲ្យមានការតស៊ូប្ដូរផ្ដាច់ រហូតដល់បានសម្រេចនូវជោគជ័យគួរជាទីពេញចិត្ត គឺមានការងារ និង ជីវភាពធូរជារ ។ «អ្នកប្រុសតូច» ជានាមថ្មីដែលសហការីផ្ដល់ជូនលោកនោះ មានន័យគ្រប់គ្រាន់ សម្រាប់អះអាងអំពីជោគជ័យនៃការតស៊ូនៅឯប្រទេសបារាំង ។

ជោគជ័យតែម្នាក់ឯងបែបនោះ មិនអាចធ្វើឲ្យលោកស្ងប់ចិត្តបានឡើយ ។ ក្រោយពេលដួលរលំនៃរបបសាធារណរដ្ឋខ្មែរ នៅថ្ងៃ ១៧ មេសា ១៩៧៥ ដំណឹងអំពីអំពើឃោរឃៅនៃរបបប៉ុលពត បានធ្វើឲ្យលោកងាកមករកស្វែងយល់អំពីសភាពការណ៍ស្រុកទេសរបស់ខ្លួនឡើងវិញ ។ បន្ទាប់មកទៀត ដោយការដួលរលំនៃរបបប៉ុលពត នៅថ្ងៃទី ៧ មករា ១៩៧៩ មិនទាន់នាំមកនូវសន្តិភាព

ទាំងស្រុងដល់ប្រទេសកម្ពុជានៅឡើយនោះ លោកបានកំណត់នូវផ្លូវដែលត្រូវដើរនៅក្នុងដំណាក់កាលថ្មី ។

លោកបានលះបង់សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីចូលប្រឡូកក្នុងជួររណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ) នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ។ គឺចាប់ពីពេលនោះហើយ ដែលជីវិតរបស់លោកស្ថិតនៅលើផ្លូវបត់បែនមករកសន្តិភាព ។ នេះជាខ្លឹមសារទី៣នៃស្នាដៃ ដែលលាតត្រដាងតាមរយៈសកម្មភាពរបស់លោកនៅក្នុង រ.ជ.រ.ប.ខ ។

នៅឆ្នាំ ១៩៧៩ សង្គ្រាមឥណ្ឌូចិនលើកទី៣បានផ្ទុះឡើង ហើយទឹកដីកម្ពុជាបានក្លាយជាសមរភូមិក្តៅ ។ បណ្តាមហាអំណាចលោកសេរី និង កុម្មុយនីស្តនៅប្រឈមមុខគ្នាយ៉ាងខ្លាំងក្លានៅឡើយ នៅដំណាក់កាលចុងក្រោយនៃសង្គ្រាមត្រជាក់ ។ ក្រៅពីពួកប៉ុលពតដែលមានបាតដៃជាប់ជិតដាមដោយស្នាមលោហិតនោះ កូនខ្មែរជាច្រើននៅក្នុងចលនាតស៊ូនានាពីគ្រប់ទិសទី បានរួមចំណែកក្នុងការស្តាបនាសន្តិភាព សម្រាប់ជាតិមាតុភូមិរបស់ខ្លួនឡើងវិញ ។

លោក អៀង មូលី ដែលជាអ្នកនិពន្ធស្នាដៃនេះ ក៏បានលះបង់យុវវ័យដ៏ផូរផង់របស់លោកដោយអង់អាច និង ប្រកបដោយមនសិការជាតិ ដើម្បីរួមចំណែកក្នុងការស្តាបនាសន្តិភាពឡើងវិញផងដែរ ។ សៀវភៅដែលមានចំណងជើងថា «ជីវិតលើផ្លូវបត់បែនទៅរកសន្តិភាព» ឆ្លុះបញ្ចាំងពិតប្រាកដនូវការតស៊ូប្រកបដោយការប្តេជ្ញាចិត្តកម្រិតខ្ពស់របស់អ្នកនិពន្ធ ដែលបានស្គាល់គ្រប់រសជាតិនៃជីវិត គឺការលំបាក ការងាយស្រួល បរាជ័យ និង ជោគជ័យ ដែលមានអត្ថន័យដ៏ជ្រាលជ្រៅសម្រាប់ជីវិតផ្ទាល់ខ្លួនផង និង សម្រាប់វាសនានៃជាតិមាតុភូមិផង ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ មីនា ២០១៣

បណ្ឌិតសភាចារ្យ ស៊ន សំណាង

# អារម្ភកថា

ជាយូរមកហើយ ខ្ញុំតែងតែមានគំនឹតចង់ឃើញខ្មែរយើងសរសេរអំពីរឿងរ៉ាវរបស់ខ្មែរដោយជនជាតិខ្មែរខ្លួនឯង ព្រោះថាសៀវភៅអំពីខ្មែរភាគច្រើនៗតែត្រូវបានសរសេរដោយអ្នកនិពន្ធជនជាតិបរទេស ជាពិសេស អ្នកនិពន្ធនៃប្រទេសលោកខាងលិច ។ ខ្ញុំនឹកដល់អ្នកចេះដឹង អ្នកមានបទពិសោធន៍ក្នុងឆាកជីវិតខាងផ្នែកវិជ្ជាជីវៈខាងផ្នែកសិល្បៈ ឬ ខាងផ្នែកនយោបាយដែលប្រាកដជាមានប្រធានបទយ៉ាងច្រើនទាក់ទងនិងជីវិតរបស់គេម្នាក់ៗ ។ ប្រសិនបើគេសរសេរ បោះពុម្ព និង ផ្សព្វផ្សាយនូវបទពិសោធន៍ ឬ រឿងរ៉ាវទាំងឡាយដែលអ្នកទាំងនោះបានជួបប្រទះ នោះអនុជនជំនាន់ក្រោយអាចយកទៅពិចារណា ឬ រៀនសូត្រទុកជាមេរៀនបាន ។

ចំពោះរូបខ្ញុំដំបូងឡើង ខ្ញុំសរសេរសៀវភៅនេះ ជារបៀបជីវប្រវត្តិសម្រាប់ទុកឲ្យកូនចៅខ្ញុំយល់ដឹងពីទឹកដី ភូមិកំណើត និង ខ្សែស្រឡាយនៃត្រកូល អៀងតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែ ដោយសារខ្ញុំបានឆ្លងកាត់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាងប្រាំមួយទសវត្សរ៍មកនោះ ជួនកាលក្នុងឋានៈជាពលរដ្ឋសាមញ្ញធម្មតា ដែលទទួលរងនូវផលប៉ះពាល់ ជួនកាលជាអ្នកសង្កេតការណ៍ និង ជួនកាលមួយផ្នែកតូចក្នុងឋានៈជាតួអង្គមួយ ឬ ជាសាក្សីរស់ម្នាក់ ខ្ញុំក៏មានគំនិតបើកទូលាយឲ្យសាធារណជនយល់ដឹងផងនូវហេតុការណ៍ទាំងនោះ ។ សៀវភៅនេះ ក៏ក្លាយទៅជាសំណេរអំពីបញ្ហាសង្គម សេដ្ឋកិច្ច និង នយោបាយនៃប្រទេសកម្ពុជាយើង តាមការចងចាំ ឬ តាមការយល់ដឹងផ្ទាល់ និង តាមឯកសារស្រាវជ្រាវបន្ថែម ។ ទាំងនេះក៏ដោយសារខ្ញុំយល់ថាសៀវភៅអំពីខ្មែរ សរសេរដោយខ្មែរនៅមិនទាន់សម្បូណ៌បែបនៅឡើយ ។

បូកផ្សំជាមួយរឿងរ៉ាវផ្ទាល់របស់ខ្ញុំ សៀវភៅនេះមួយផ្នែកជារឿងដំណាល

អំពីប្រវត្តិសាស្ត្រ ឬ អំពីព្រឹត្តិការណ៍សង្គមជាតិពីជំនាន់មួយ ទៅជំនាន់មួយ ជាពិសេសព្រឹត្តិការណ៍ ដែលកើតមាននៅទសវត្សរ៍ចុងក្រោយៗនេះ ។ កុមារភាពរបស់ខ្ញុំចាប់ផ្តើមនៅក្នុងសង្គមខ្មែរមួយ ដែលកាន់ព្រះពុទ្ធសាសនា ប្រកាន់ទំនៀមទម្លាប់ គោរពរាជានិយម និង នៅក្នុងបរិបទនយោបាយមួយដែលកំពុងឈានចេញពីសម័យអសន្តិសុខឆ្ពោះទៅរកសម័យឯករាជ្យជាតិ ។ ក្នុងមួយរយៈ នៅសម័យប្រទេសជាតិស្ថិតនៅក្នុងសន្តិភាព រូបខ្ញុំក៏ដូចជាក្មេងៗខ្មែរឯទៀត បានចំរើនធំធាត់ឡើងដោយមិនដែលនឹកថា ថ្ងៃណាមួយខាងមុខប្រជាជាតិនឹងជួបនូវក្តីមហន្តរាយសោះឡើយ ។ នៅសម័យសន្តិភាពនោះ ប្រជារាស្ត្រខ្មែរភាគច្រើន មានជំនឿជឿជាក់លើការដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ ដែលអ្នកស្រុកជាទូទៅហៅព្រះអង្គថាសម្តេចឪ និង ដែលគេនាំគ្នាគោរពទុកជាទីសក្ការៈខ្ពស់ស្មើរស្មើអង្គព្រះពុទ្ធ និង ព្រះអាទិទេពជាម្ចាស់ ។ ម្នាក់ៗជឿថារបបគ្រប់គ្រងរដ្ឋរបស់ព្រះអង្គនឹងនៅស្ថិតស្ថេរគង់វង្សជាអមតៈ គ្មានអ្វីអាចធ្វើឲ្យរង្គោះរង្គើ ឬ ដួលរលំបានឡើយ ។ ក៏ប៉ុន្តែ ព្រេងវាសនាប្រទេសជាតិមិនត្រូវបានចារដូចពួកយើងនឹកស្រមៃនោះទេ ។

ចាប់ពីខែ មីនា ១៩៧០ ភ្លើងសង្គ្រាមបានឆេះសន្ធោសន្ធៅនៅកម្ពុជារហូតនាំមកនូវរបបប្រល័យពូជសាសន៍ឯងមួយ(An Auto-Genocidal Regime) ដែលកម្រឃើញមាននៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិយើងនេះ ។ ប្រជាជាតិ និង ប្រជារាស្ត្រខ្មែរទាំងមូលទទួលរងនូវមហាវិនាសកម្ម ដែលពិបាករកពាក្យមកថ្លែងឲ្យសម ឬ ឲ្យចំបានឡើយ ។ អ្នកនៅក្នុងប្រទេសទទួលរងនូវការកាប់សម្លាប់ ការបង្អត់អាហារ ការបង្ខំឲ្យធ្វើការជាទម្ងន់ ព្រមទាំងការនិរាសព្រាត់ប្រាសប្រពន្ធ ប្តី កូនចៅបងប្អូន ញាតិមិត្រជាទីស្រឡាញ់ជាដើម ធ្វើឲ្យបាត់បង់អស់នូវសិទ្ធិ និង សេរីភាពដែលជាសេចក្តីថ្លៃថ្នូររបស់មនុស្ស ។ អ្នកទ្រាំមិនបាន ក៏លបលួចរត់ចេញទៅក្រៅប្រទេស ។ អ្នកខ្លះក៏រើបំរះ ក្រោកឡើង បង្កើតជាចលនាតស៊ូប្រដាប់អាវុធប្រឆាំង

របប ប៉ុល ពត ។

ខ្សែជីវិតក្នុងយុវវ័យរបស់ខ្ញុំ ក៏អណ្តែតត្រសែតទៅតាមកម្លាំងបោកបក់នៃព្យុះភ្លើងសង្គ្រាម ។ នៅប្រទេសបារាំង បែកពីឪពុកម្តាយ និង ដោយឯកោម្នាក់ឯងជីវិតជាជនភៀសខ្លួនរបស់ខ្ញុំ ដែលបានឆ្លងកាត់ឧបសគ្គមួយចំនួនរួចហើយនោះមិនបានកាត់ផ្តាច់ឬសគល់ឈាមជ័រជាខ្មែររបស់ខ្ញុំបានឡើយ ។ ព្រឹត្តិការណ៍ទាំងឡាយនាទសវត្សរ៍ឆ្នាំ ១៩៧០ បាននាំឲ្យខ្ញុំចូលប្រឡូកក្នុងឆាកនយោបាយដែលចាប់ផ្តើមឡើងនៅក្រៅប្រទេស ។ ក្នុងការចូលរួមក្នុងជួររណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ) នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ គំនឹតចម្បងដំបូងនៃការតស៊ូរបស់ខ្ញុំនោះគឺធ្វើការប្រឆាំងរបប ប៉ុល ពត ដើម្បីរំដោះប្រជាពលរដ្ឋខ្មែរពីទាសភាព ។ ក៏ប៉ុន្តែដោយឈរជើងលើភូមិសាស្ត្រនយោបាយមួយដែលអនុគ្រោះដល់ខ្មែរក្រហម ប៉ុល ពត នោះ រណសិរ្សនេះមិនត្រឹមតែផ្អាកការតស៊ូប្រឆាំង ប៉ុល ពត ប៉ុណ្ណោះទេ ផ្ទុយទៅវិញ ថែមទាំងបានសហការជាមួយពួកប្រល័យពូជសាសន៍នេះនៅក្នុងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យហៅថារដ្ឋាភិបាលត្រីភាគីទៀតផង ។ នោះគឺជាសម្ព័ន្ធភាពមួយ ដែលមានខ្មែរក្រហមជាកម្លាំងស្នូល ។ នេះជាសំណើចចំអកនៃព្រហ្មលិខិត។

នៅក្នុងបរិបទនៃភូមិសាស្ត្រនយោបាយនាសម័យនោះ មនុស្សភាគច្រើននៃសម្ព័ន្ធភាពត្រីភាគី សម្លឹងឃើញវត្តមានកងទ័ពវៀតណាមនៅកម្ពុជាថាជាការកាន់កាប់ទឹកដីខ្មែរដោយកងទ័ពនេះ ។ ដូច្នេះ វត្តមាននៃកងទ័ពវៀតណាមនៅកម្ពុជាក៏ក្លាយជាប្រធានបទនៃការឃោសនារបស់ពួកខ្មែរក្រហម ក្នុងការស្វែងរកកាគ្រាំទ្រពីក្នុង និង ពីក្រៅប្រទេស ។ តាមពិត ចាប់តាំងពីមានការបោះឆ្នោតសកលនៅឆ្នាំ ១៩៩៣ រហូតមក ពាក្យឃោសនាអំពីវៀតណាមត្រួតត្រាកម្ពុជា លែងមានន័យអ្វី

ទាំងអស់រួចទៅហើយ ។ ក៏ប៉ុន្តែ ប្រធានបទបែបនេះក៏នៅត្រូវបានអ្នកលេងល្បែងនយោបាយយកមកប្រើតទៅទៀតរហូតទល់សព្វថ្ងៃ ដើម្បីដណ្តើមប្រៀបខាងផ្នែកនយោយបាយ ។

សៀវភៅនេះ រៀបរាប់អំពីប្រវត្តិនៃចលនាតស៊ូប្រឆាំងវៀតណាម ជាពិសេសអំពីរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ) ដែលខ្ញុំធ្លាប់កាន់តំណែងជាអគ្គលេខាធិការ និង អំពីការកកើតនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងតួនាទីរបស់អ្នកដឹកនាំនៃរដ្ឋាភិបាលនេះ រួមទាំងតួនាទីដ៏សំខាន់របស់សម្តេចព្រះ នរោត្តម សីហនុ ផង ។ តាមពិត សម្ព័ន្ធភាពត្រីភាគីជួយបន្តជីវិតនយោបាយរបស់ខ្មែរក្រហម ប៉ុល ពត បានមួយរយៈពេលទៀត ។ ជម្លោះផ្ទៃក្នុងនៅក្នុងជួររ.ជ.រ.ប.ខ.ដែលធ្វើឲ្យរណសិរ្ស សឺន សាននិយម ចុះអន់ថយ និង ទន់ខ្សោយជាលំដាប់នោះត្រូវបានលើកមករៀបរាប់ ។ ជាមួយនោះ ក៏មានលើកឡើងអំពីការប្រណាំងប្រជែងគ្នារវាងចលនាតស៊ូមិនមែនកុម្មុយនីស្ត និង អំពីឧត្តមភាពយោធាផ្តាច់មុខរបស់ខ្មែរក្រហមទៅលើដៃគូទាំងពីរក្នុងរដ្ឋាភិបាលចម្រុះត្រីភាគី ។ ការលើកឡើងទាំងនោះបង្ហាញអំពីចំណុច ដែលនាំឲ្យសម្ព័ន្ធភាពត្រីភាគីមិនអាចទទួលជោគជ័យ និង ជាហេតុផលមួយជំរុញសម្តេចព្រះ នរោត្តម សីហនុ ឲ្យស្វែងរកវិធីជួបចរចាផ្ទាល់ជាមួយមេដឹកនាំក្រុងភ្នំពេញ ។ គោលជំហរនេះផ្ទុយស្រឡះពីគោលជំហររបស់ខ្មែរក្រហម និង ក្រុម សឺន សាននិយម ។

ដោយរបប ប៉ុល ពត ជាសត្រូវរួមរបស់ខ្មែរ ចលនាប្រឆាំង ប៉ុល ពត នៅក្នុងប្រទេសក៏បានផ្ទុះឡើងតាំងពីឆ្នាំ ១៩៧៧ ។ នៅក្នុងចលនាតស៊ូនោះ ប្រធានកងវរសេនាធំមួយរូប ដែលកំពុងស្ថិតក្នុងយុវវ័យនៅឡើយនាសម័យនោះ បានបង្ហាញនូវការប្តេជ្ញាចិត្តដ៏មោះមុត និង សេចក្តីក្លាហានដ៏រឹងមាំអស្ចារ្យកម្រមាននៅ

ក្នុងប្រវត្តិសាស្ត្រកម្ពុជា រហូតដល់សម្រេចជោគជ័យផ្ដួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត បានទាំងស្រុង ។ ដូច្នេះហើយបានជាសៀវភៅនេះ ក៏បានលើកយកមកអធិប្បាយនូវប្រវត្តិវីរភាពនោះ ដែលជាប្រវត្តិតស៊ូរបស់សម្ដេចតេជោ ហ៊ុន សែន បច្ចុប្បន្ននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ សម្ដេចតេជោជាមេដឹកនាំខ្មែរមួយ រូបដែលកើតចេញពីត្រកូលកសិករខ្មែរសុទ្ធសាធ ។ លោកត្រូវបានគូបដិបក្ខវាយតម្លៃខុសលើសមត្ថភាពកាងារដឹកនាំ ។ ទីបំផុត អង្គការចាត់តាំងរបស់ខ្មែរក្រហម ប៉ុល ពត ទាំងនយោបាយ ទាំងយោធា បានត្រូវរំលាយចោលជាស្ថាពរដោយសារនយោបាយឈ្នះ/ឈ្នះរបស់សម្ដេចតេជោនៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ ។ នយោបាយឈ្នះ/ឈ្នះនេះ ជាប្រធានបទនៃការស្រាវជ្រាវដោយឡែក នៅក្នុងសៀវភៅមួយទៀត ។

តាមធម្មតា យុវជនច្រើនប្រកាន់យកឧត្ដមគតិស្រឡាញ់អំពើស្អាតស្អំ យុត្តិធម៌សង្គម និង មានស្មារតីស្នេហាជាតិខ្ពស់ ។ នៅពេលស្រុកកើតសង្គ្រាមជាមួយបរទេសឈ្លានពាន ពួកគេច្រើនស្ម័គ្រចិត្តធ្វើជាទាហានការពារទឹកដី ។ បើមានបដិវត្តន៍ យុវជនភាគច្រើនស្ម័គ្រចិត្តធ្វីជាកម្លាំងឈានមុខ ឬ កម្លាំងស្រួចនៃបដិវត្តន៍នោះ ។ សម្ដេចតេជោ ហ៊ុន សែន ដែលជាយុវជនម្នាក់នាទសវត្សរ៍ឆ្នាំ ១៩៧០ ស្ថិតនៅក្នុងចំណោមយុវជនខាងលើ ។ ចំណែកឯរូបខ្ញុំៗចូលរួមធ្វើសកម្មភាពដំបូងប្រឆាំង ប៉ុល ពត ដែរ ក៏ប៉ុន្តែភូមិសាស្ត្រនយោបាយសម័យនោះ តម្រូវឲ្យចូលរួមក្នុងសម្ព័ន្ធភាពត្រីភាគីទៅវិញ ។ នៅក្នុងសៀវភៅរបស់លោកក្រោមចំណង ជើងថា «១០ ឆ្នាំនៃដំណើរកម្ពុជា» សម្ដេចតេជោ បានចាត់ទុកការចូលរួមណាមួយក្នុងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យនោះថាគឺជាការឡើងជិះនាវារបស់ខ្មែរក្រហម ។ ការចាត់ទុកនេះពិតជាត្រឹមត្រូវ ។

ការលើកឡើងអំពីសកម្មភាពចលនាតស៊ូប្រឆាំងកងទ័ពវៀតណាម នៅទសវត្សរ៍ឆ្នាំ ១៩៨០ អាចពិពណ៌នាបានថាជាការបង្ហាញអំពីទស្សនិយភាពលេចចេញពីការធ្វើដំណើរតាមកប៉ាល់របស់ខ្មែរក្រហមនោះឯង ។ ការស្រុះស្រួលគ្នាបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជាហៅកាត់ថា អេស អិន ស៊ី (SNC: Supreme National Council) បានផ្តល់លទ្ធភាពឲ្យខ្ញុំអាចលោតចេញពីនាវា «កម្ពុជាប្រជាធិបតេយ្យ» មកជិះនាវាជាតិដ៏ធំវិញម្តង ។ ចាប់តាំងពីបានមកដល់ភ្នំពេញ នៅចុងឆ្នាំ ១៩៩១ ខ្ញុំបានប្តេជ្ញាថាមិនវិលត្រឡប់ទៅធ្វើការតស៊ូនៅតាមទល់ដែនខ្មែរ-ថៃទៀតទេ ។ ខ្ញុំនៅចាំបានថានៅខែ កក្កដា ១៩៩២ តាមរថយន្តជិះជាមួយគ្នាពីឧដុង្គមកភ្នំពេញ បន្ទាប់ពីបានចូលរួមក្នុងពិធីរុក្ខទិវា លោកឯកអគ្គរដ្ឋទូតអាមេរិក ឆាលត្វាយនីង (Charles Twining) សួរខ្ញុំថាប្រសិនបើមានហេតុការណ៍អាក្រក់អ្វីកើតឡើង តើអ្នកត្រឡប់ទៅធ្វើការតស៊ូតាមជាយដែនឬទេ? ខ្ញុំឆ្លើយថាទេ! ខ្ញុំមិនត្រឡប់ទៅទល់ដែនវិញជាដាច់ខាត ព្រោះខ្ញុំមានបទពិសោធន៍ឆ្អែតឆ្អន់អស់ហើយ ។ ខ្ញុំសង្កត់ធ្ងន់ថា ខ្ញុំនឹងប្រឹងប្រែងឲ្យអស់សមត្ថភាព ដើម្បីចូលរួមធ្វើឲ្យមានការបោះឆ្នោត ។ បញ្ហាការចូលរួមបោះឆ្នោត ឬ មិនចូលរួមបោះឆ្នោតនៅឆ្នាំ ១៩៩៣ នោះ ជាចំណុចផ្លូវបំបែក ដែលត្រូវដើរផ្សេងគ្នារវាងខ្ញុំនិង សម្តេច សឺន សាន ។ ខ្ញុំប្រកាន់ជំហរឥតប្រែប្រួលថាត្រូវតែចូលរួមបោះឆ្នោត រីឯក្រុម សឺន សាននិយមនៅទីទើរ ម្តងថាមិនចូលរួម ម្តងថាសុំពន្យារពេលបោះឆ្នោត ។ ជាសំណាងល្អ និង ទោះបីមានឧបសគ្គច្រើនយ៉ាងណាក៏ដោយ ខ្មែរយើងទាំងអស់ស្ទើរតែទូទាំងប្រទេស លើកលែងតែអ្នកនៅក្នុងតំបន់ខ្មែរក្រហមកាន់កាប់ប៉ុណ្ណោះ បាននាំគ្នាទៅបោះឆ្នោតយ៉ាងគគ្រឹកគគ្រេងនៅឆ្នាំ ១៩៩៣ ។ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ជាច្បាប់កំពូល សម្រាប់ធ្វើជាដំបូលតែមួយ ឲ្យគ្រួសារខ្មែរគ្រប់និន្នាការនយោបាយអាចជ្រកកោន និង រួមរស់ជាមួយគ្នាដោយសុខដុមរមនា ។

នៅទីបំផុត ខ្ញុំក៏បានចូលរួមក្នុងគណបក្សប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចទាំងបី ដើម្បីបំរើប្រជាជន និង ប្រជាជាតិតទៅទៀត ។ គណបក្សខ្មែរដ៏ធំនេះ មានប្រពៃណីផ្សារភ្ជាប់ជោគវាសនារបស់ខ្លួនទៅជាមួយជោគវាសនារបស់ប្រជាជនទាំងមូល ។ នេះជាជីវិតនយោបាយរបស់ខ្ញុំ ដែលជាជីវិតលើផ្លូវបត់បែនមួយ ។ នេះជាផ្លូវបត់បែនឆ្ពោះទៅរកសន្តិភាព។ នៅភាគទីមួយ សៀវភៅនេះនិយាយត្រឹមជំនួប សីហនុ - ហ៊ុន សែន នាចុងឆ្នាំ ១៩៨៧ ព្រោះនោះជាចំណុចគន្លឹះ ដើម្បីទំលុះភាពទាល់ច្រក បើកផ្លូវឲ្យមានការចរចាជាបន្តបន្ទាប់ឈានទៅរកដំណោះស្រាយទិដ្ឋភាពផ្ទៃក្នុងនៃបញ្ហាកម្ពុជា ។

ដោយបានសិក្សាលើឯកសារជាង ២០០០ ច្បាប់ អត្ថបទកាសែត សៀវភៅអំពីកម្ពុជា និង កំណត់ចំណាំមួយចំនួន ខ្ញុំសង្ឃឹមថាសៀវភៅនេះអាចផ្តល់សារប្រយោជន៍ខ្លះៗដល់អ្នកអាន ឲ្យអាចយល់ដឹងអំពីបញ្ហាស្រុកទេសនាទសវត្សរ៍កន្លងមក ។ សៀវភៅនេះ មានចំណុចលម្អិតជាច្រើន ដែលអស់លោកអ្នកអានអាចសំគាល់ថាឥតប្រយោជន៍ ។ ក៏ប៉ុន្តែដោយមួយផ្នែកពាក់ព័ន្ធជាមួយជីវប្រវត្តិឯកជន ចំណុចលម្អិតនោះ ត្រូវរក្សាទុក ។ ខ្ញុំជឿថា សៀវភៅនេះក៏ប្រាកដជាទទួលរងនូវការរិះគន់ ឬ វាយតម្លៃទាប ខ្ពស់ តាមមនោសញ្ចេតនា ឬ និន្នាការនយោបាយរបស់អ្នកអាន ។ ខ្ញុំសរសេរសៀវភៅនេះ ទៅតាមដំណើរជីវិតជាក់ស្តែង និង ព្រឹត្តិការណ៍ ដែលខ្ញុំយល់ដឹង ដោយព្យាយាមប្រើបញ្ញា មិនប្រើបេះដូង ព្រោះថាបើសរសេរទៅតាមមនោសញ្ចេតនា សំណេរនេះអាចទោរទន់ ទៅតាមការស្អប់ការស្រឡាញ់ ការភ័យខ្លាច ដែលនឹងឃ្លាតចេញឆ្ងាយពីការពិត ។

ដូចខ្ញុំបានលើកពីខាងដើម ខ្ញុំចង់ឃើញខ្មែរសរសេរអំពីរឿងរ៉ាវខ្មែរឲ្យបានច្រើន ដើម្បីចូលរួមកសាងធនធានបញ្ញាញាណរបស់ជាតិយើងឲ្យធំទូលំទូលាយ ។

ខ្ញុំធ្លាប់បានស្ដាប់ពាក្យនិទានរបស់ពលរដ្ឋខ្មែរជាច្រើន ជាពិសេស ពីជនរួមឈាមដែលឆ្លងកាត់របប ប៉ុល ពត ។ អ្នកទាំងនោះមានរឿងរ៉ាវនិយាយមិនចេះចប់ ។ ក៏ប៉ុន្តែ ខ្ញុំក៏យល់ដែរថា អ្នកសរសេររឿងរ៉ាវទាំងអស់នោះ នឹងមានទឹកចិត្តសរសេរ តែក្នុងករណីមានអ្នកអាន ។ បើគ្មានអ្នកអាន គេមិនដឹងសរសេរដើម្បីអ្វី ។ យើងគួរនាំគ្នាអានសៀវភៅឲ្យបានច្រើន រហូតបង្កើតឲ្យបានទៅជាទម្លាប់នៃការអានសៀវភៅ សមដូចពាក្យស្លោកថា អានច្រើន បង្កើនបញ្ញា ។ នៅក្នុងប្រទេសអភិវឌ្ឍជាច្រើន គេផ្ដល់អាទិភាពនៃការវិនិយោគទៅលើការកសាង និង ការពង្រឹងធនធានបញ្ញាញាណ ។ សៀវភៅនេះនៅក្រោមចំណងជើងថា៖ «ជីវិតលើផ្លូវបត់បែនទៅរកសន្តិភាព» ជាការរួមចំណែកដ៏តូចស្ដួចស្តើងមួយរបស់ខ្ញុំក្នុងការកសាងធនធានបញ្ញាញាណរបស់ខ្មែរ ដែលយើងម្នាក់ៗត្រូវចូលរួមក្នុងពេលនេះ និង ពេលអនាគតខាងមុខកុំបីអាក់ខានឡើយ ។

# កម្រងពាក្យសរសេរកាត់ជាភាសាខ្មែរ

| | |
|---|---|
| ក.ជ.រ.ប.ខ | កងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ ( KPNAF) |
| កូម៉ិច | គណៈកម្មាធិការប្រតិបត្តិ ( COMEX ) |
| រ.ជ.រ.ប.ខ | រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ( KPNLF ) |
| អ.ស.ប | អង្គការសហប្រជាជាតិ ( UN ) |
| អាស៊ាន | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN ) |
| អេស សេ អេហ្វ | សង្គមវិជ្ជាជីវៈគណនេយ្យនៃប្រទេសបារាំង ( SCF ) |
| អេស អិន ស៊ី | ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា (SNC ) |
| អា ហ្សេ កា អឺ | សមាគមទូទៅខ្មែរនៅបរទេស ( AGKE ) |
| ពែកមីកូ | គណៈកម្មាធិការសហការយោធា ( PERMICO ) |
| ហ្វ៊ុនស៊ិនប៉ិច | រណសិរ្សរួបរួមជាតិ ដើម្បី កម្ពុជា ឯករាជ្យ អព្យាក្រឹត្យ សន្តិ និង សហប្រតិប្តការ ( FUNCINPEC ) |

# កម្រងពាក្យសរសេរកាត់ជាភាសាបរទេស

| | |
|---|---|
| AGKE | Association des Khmers à l′Etranger |
| ASEAN | Association of Southeast Asian Nations |
| CGDK | Coalition Government of Democratic Kampuchea |
| COMEX | Comité Exécutif |
| FUNCINPEC | Front Uni National pour un Cambodge Indépendant Neutre Et Coopératif |
| KPNAF | Khmer People′s National Liberation Armed Forces |
| KPNLF | Khmer People′s National Liberation Front |
| PERMICO | Permanent Military Committee for Coordination |
| PCCS | Provisional Central Committee for the Salvation of KPNLF |
| SNC | Supreme National Council |
| SCF | Société de Comptabilité de France |




នៅលើផែនទីខេត្តព្រៃវែង សព្វថ្ងៃផ្លូវជាតិលេខ ៨ ភ្ជាប់ពីស្ពានព្រែកតាមាក់ ទៅអន្លង់ជ្រៃ និង ពញាក្រែក
នៃខេត្តកំពង់ចាម ។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ខ្ញុំធ្លាប់ជិះកង់ តាមកំណាត់ផ្លូវនេះ ដើម្បីធ្វើដំណើរទៅភ្នំពេញ

ប្រភពផែនទី វេបសាយក្រសួងសាធារណការ